# ការរក្សាប្រើភាសាទីមួយ/ភាសាកំណើតផ្តល់មូលដ្ឋាន ដ៏រឹងមាំសម្រាប់ការសិក្សាភាសាអង់គ្លេស។

ភាសាទីមួយដែលរៀននៅផ្ទះមានសារៈសំខាន់ណាស់ និង បង្កើតមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍចំណេះដឹងផ្នែកសាភា ទាំងអស់នៅពេលខាងមុខ។

កុមារអាចចាប់យកភាសាពីរ ឬច្រើនជាងនេះ នៅពេលពួក គេមានឱកាសឮគេនិយាយ និងប្រាស្រ័យទាក់ទងដោយប្រើ ភាសាច្រើន។

មាតាបីតា សមាជិកគ្រួសារ និង អ្នកអប់រំ គឺជាអ្នកដែល មានឥទ្ធិពលជាងគេបង្អស់ទៅលើការអភិវឌ្ឍចំណេះដឹង និង រក្សាប្រើភាសាកំណើត។ មាតាបីតាអាចជួយ ដោយប្រើភាសា កំណើតឲ្យបានជាប់ជាប្រចាំ នៅពេលពួកគេប្រាស្រ័យ ទាក់ទងជាមួយកូន ហើយដោយមិននិយាយភាសាអង់គ្លេស។

មានមូលហេតុជាច្រើនដែលបញ្ជាក់ថាហេតុអ្វីបានជាមាតាបីតា ចាំបាច់ត្រូវរក្សាប្រើភាសាទីមួយ ឬភាសាកំណើត ៖

- នៅពេលកុមារនិយាយភាសាកំណើតបានស្ទាត់ ចំណេះនេះ អាចជួយឲ្យកុមារក្នុងការសិក្សាភាសាទីពីរ។
- ការរក្សាប្រើភាសាកំណើតមានភាពចាំបាច់ណាស់ដើម្បី បង្កើតឲ្យមានអារម្មណ៍ស្ងប់ក្នុងចិត្ត ចំណងទាក់ទងជាមួយ គ្រួសារ និងវប្បធម៌ ហើយឲ្យមានការយល់ដឹងពីកម្មសិទ្ធិ។
- ការចេះច្រើនភាសាបានល្អពង្រីកភាពបត់បែននៃការគិត របស់កុមារ និង ជះឥទ្ធិពលវិជ្ជមានដល់ឥរិយាបថក្នុង ការសិក្សា ដោះស្រាយបញ្ហា និង លទ្ធផលការសិក្សា របស់ពួក។

កុមារត្រូវការឮគេនិយាយភាសាកំណើត ដែលប្រើក្នុងស្ថាន ភាពផ្សេងៗគ្នា និង សម្រាប់គោលបំណងផ្សេងៗគ្នា។ ការធ្វើបែបនេះជួយអភិវឌ្ឍការយល់ដឹងច្បាស់ពីអត្តសញ្ញាណ និង ផ្តល់មូលដ្ឋានគ្រឹះសម្រាប់សិក្សាភាសាអង់គ្លេស។










# ការសិក្សាភាសាអង់គ្លេសជាភាសាបន្ថែម ក្នុងកន្លែងថែទាំកុមារតូច។

កុមារនឹងមានឱកាសជាច្រើនដើម្បីសិក្សាភាសាអង់គ្លេស ក្នុងកន្លែងថែទាំកុមារតូច។

កុមារចូលរួមយ៉ាងឆាប់រហ័សក្នុងបរិស្ថានដែលពួកគេនឹងឮគេ និយាយភាសាអង់គ្លេសក្នុងបរិបទផ្សេងៗគ្នាជាច្រើន។ ពួកគេ នឹងចង់ចូលរួមនៅក្នុងការលេងជាមួយក្មេងដទៃទៀត។ អ្នក អប់រំនឹងផ្តល់គំរូល្អ និងឱកាសជាច្រើនសម្រាប់កុមារដើម្បីឮគេ និយាយ និង អនុវត្តភាសាអង់គ្លេស។ អ្នកអប់រំនឹងណែនាំ និង លើកទឹកចិត្តកុមារ នៅពេលពួកគេរៀនចេះយល់ និងនិយាយ ភាសាអង់គ្លេសបានជាបណ្តើរៗ។

កុមារអភិវឌ្ឍបំណិនភាសារបស់ពួកគេទៅតាមល្បឿនរបស់ពួក គេ។ កុមារដែលសិក្សាពីរភាសានៅពេលតែមួយអាចនិយាយ ភាសាមួយច្រើនជាងភាសាមួយផ្សេងទៀត ក្នុងអំឡុងពេល មួយ។ ជាដំបូង កុមារអាចប្រើភាសាលាយគ្នានៅពេលពួកគេ និយាយ។ ពួកគេអាចស្គាល់ពាក្យជាភាសាមួយ ហើយមិន ស្គាល់ពាក្យនេះជាភាសាមួយទៀត។ កុមារប្រើពាក្យដែល ពួកគេចេះ ដើម្បីរក្សាឲ្យពួកគេសន្ទនាបានស្ទាត់។

ជាការសំខាន់នៅពេលដែលកុមារកំពុងសិក្សាភាសាអង់គ្លេស ជាភាសាបន្ថែម មាតាបីតាបន្តនិយាយភាសាកំណើតជាមួយ កូនពួកគេ។ ការធ្វើបែបនេះជួយកូនអ្នកឲ្យអភិវឌ្ឍ និង រក្សាប្រើភាសាកំណើតបាន។










Information for families: Handout 1 - Khmer

ព័ត៌មានសម្រាប់គ្រួសារ: ក្រដាសព័ត៌មានទី ១

fka CHILDREN'S SERVICES INC
Incorporating Multicultural Resource Centre

Ground Floor, 9-11 Stewart Street
Richmond, 3121
tel: +61 3 9428 4471
fax: +61 3 9429 9252
email: fkacs@fka.org.au
web: www.fka.org.au
FKA Children's Services Inc. 215663278505573